**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៧៥០ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០២៩៥/ ១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ អប្សរា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ អប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលមាត្រា៤ និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ អប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/០៧ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤ ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៥/៣២៣ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីការប្រគល់រមណីយដ្ឋានប្រាសាទកោះកេរ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរ អប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៧/០១៥ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលមាត្រា២ ជំពូកទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ អប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៦១៣ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា៤ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ អប្សរា
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ មានឋានៈស្មើ នាយកដ្ឋាន ចំណុះអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ។/

**មាត្រា ២.-**

មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ មានតួនាទី និងភារកិច្ចដូចតទៅ ៖

-រៀបចំកម្មវិធី និងក្របខណ្ឌយុទ្ធសាស្ត្ររួម សម្រាប់ធ្វើការស្រាវជ្រាវបេតិកភណ្ឌរូបី និងអរូបី និងវិស័យផ្សេងទៀតពាក់ព័ន្ធនឹងការគ្រប់គ្រងឧទ្យានអង្គរ និងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា

-ពិនិត្យ និងផ្តល់យោបល់លើសំណើស្រាវជ្រាវរបស់ដៃគូជាតិ និងអន្តរជាតិនៅក្នុងឧទ្យានអង្គរ និងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា

-រៀបចំពិនិត្យអនុស្សារណៈនៃការយោគយល់ (MOU) ជាមួយដៃគូអន្តរជាតិដែលស្រាវជ្រាវនៅក្នុងឧទ្យានអង្គរ និងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា

-ទំនាក់ទំនង តាមដាន និងសហការជាមួយដៃគូជាតិ និងអន្តរជាតិដែលមកស្រាវជ្រាវនៅក្នុងឧទ្យានអង្គរ និងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា

-ប្រមូលផ្តុំរាល់ឯកសារស្រាវជ្រាវដោយដៃគូជាតិ និងអន្តរជាតិ នៅក្នុងឧទ្យានអង្គរ និងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា

-រៀបចំរបាយការណ៍ស្តីពីលទ្ធផលស្រាវជ្រាវ និងផ្សព្វផ្សាយលទ្ធផលទាំងនោះ ដើម្បីបង្កើនចំណេះដឹងជូនដល់អង្គភាព ស្ថាប័ន ដៃគូជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ

-គ្រប់គ្រង និងតម្កល់ឯកសារអង្គរ

-ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារតាមការកំណត់ ជូនអគ្គនាយកអាជ្ញាធរអប្សរា

-បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនដោយប្រធានអាជ្ញាធរអប្សរា និងអគ្គនាយកអាជ្ញាធរអប្សរា ។

**មាត្រា ៣.-**

មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានអាជ្ញាធរអប្សរា**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ